# សិវទក្សិណាមូតិ៌

ដូចយើងបានជ្រាបច្បាស់មកហើយថា នៅសម័យបុរាណឥទ្ធិពលព្រហ្មញ្ញសាសនា មានឥទ្ធិពលធំធេងខ្លាំងណាស់ក្នុងសង្គមខ្មែរ ជាពិសេស ចាប់ពីរវាងចុងស.វ.ទី៦ ដើមស.វ.ទី៧មកការប្រណិប័តន៍ព្រហ្មញ្ញសាសនា និកាយព្រះឥសូរ បានក្លាយទៅជាប្រពៃណីគោលរបស់អាណាចក្រខ្មែរទៅហើយ។ អត្ថបទមុនៗយើងបានបង្ហាញខ្លះមកហើយ អំពីទម្រង់មួយចំនួននៃការបង្ហាញព្រះឥសូរនៅក្នុងសង្គមខ្មែរសម័យបុរាណ។ ហេតុដូច្នេះ នៅក្នុងអត្ថបទខ្ញីនេះ យើងនឹងបង្ហាញព្រះឥសូរក្នុងទម្រង់ជា "មហាគុរុ" ឬគេតែងនិយមហៅម្យ៉ាងទៀតថា "សិវទក្សិណាមូតិ៌"។

"ទក្សិណាមូតិ៌" មានន័យត្រង់ថា "អ្នកដែលបែរមុខទៅទិសខាងត្បូង"។ ការបង្ហាញទម្រង់បែបនេះធ្វើឡើងនៅពេលដែលព្រះឥសូរក្លាយជាមហាគុរុ (គ្រូនៃសាស្ត្រ) ដែលជាគ្រូនៃសិល្បៈ និងវិទ្យាសាស្ត្រ គ្រូនៃពិធីសាសនានិងប្រាជ្ញាខាងវិញ្ញាណ ដើម្បីសណ្តោសដល់សត្វលោកដែលត្រូវការទ្រង់សង្គ្រោះ។[១] ជាទូទៅ ទម្រង់នេះគេបង្ហាញព្រះឥសូរគង់នៅលើផ្កាឈូក ដោយមានព្រះហស្តចំនួន៤ ក្នុងនោះព្រះហស្តឆ្វេងផ្នែកខាងក្រោមមានកាយវិការជា ធ្យានមុទ្រ (dhyana-mudra) ព្រះហស្តឆ្វេងផ្នែកខាងលើកាន់គម្ពីរ ព្រះហស្តស្តាំផ្នែកខាងក្រោមជាកាយវិការមហានិកាយ និងព្រះហស្តស្តាំផ្នែកខាងលើកាន់ផ្កា ដែលជាទម្រង់គុណលក្ខណៈរបស់ព្រះព្រហ្មផងដែរ។[២] តាមការលើកឡើងរបស់លោក Rao Gopinta TA បង្ហាញថា នៅស្រុកឥណ្ឌា គេបែងចែកភាពខុសគ្នានៃទម្រង់នេះជាច្រើនប្រភេទ ដូចជា ទម្រង់ព្រះសិវជាគ្រូនៃសាស្ត្រ ព្រះសិវវ្យខយនទក្សិណាមូតិ៌ ព្រះសិវជាគ្រូបង្រៀននៃយោគៈ និងយោគៈទក្សិណាមូតិ៌ ដោយផ្អែកទៅលើឥរិយាបថអង្គុយ ចំនួនព្រះហស្តកាយវិការនៃព្រះហស្ត និងការចូលរួមក្នុងការរៀនសូត្ររបស់ពួកឥសី។[៣]

នៅក្នុងប្រពៃណីឥណ្ឌា ការបង្ហាញទម្រង់ព្រះសិវទក្សិណាមូតិ៌ គេតែងបង្ហាញទ្រង់អង្គុយនៅលើបល្ល័ង្ករូបក្តាន់ នៅក្រោមដើមបន្យន បែរព្រះភក្ត្រទៅទិសខាងត្បូង ដោយហ៊ុមព័ទ្ធជុំវិញដោយពួកព្រាហ្មណ៍កំពុងទទួលការបំភ្លឺផ្លូវពីទ្រង់ ហើយពេលខ្លះក៏បង្ហាញជារូបសត្វព្រៃផ្សេងៗនៅហ៊ុមព័ទ្ធព្រះអង្គផងដែរ។[៤] ផ្ទុយពីស្រុកឥណ្ឌា នៅក្នុងសិល្បៈខ្មែរ អ្នកស្រាវជ្រាវមិនទាន់អាចកំណត់ទម្រង់នេះឱ្យបានច្បាស់លាស់នៅឡើយទេ ប៉ុន្តែអ្វីដែលគេសង្កេតឃើញនោះគឺ ការបង្ហាញទម្រង់ម្យ៉ាងរបស់ព្រះឥសូរ អាចស្រដៀងនឹងសិវទក្សិណាមូតិ៌នៅក្នុងសិល្បៈខ្មែរ មិនបានបែរព្រះភក្ត្រទៅទិស

---

[១] Roveda 2005.

[២] Ibid.

[៣] Rao 1914.

[៤] Rajarajan 2011.

អត្ថបទដោយៈ ម៉ង់ វ៉ាលី

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

ខាងត្បូងនោះទេ។ រូបលេខ១ រកឃើញនៅប្រាសាទសណ្ដាន់ (តំបន់ប្រាសាទសំបូរព្រៃគុក) បង្ហាញអំពីព្រះសិវក្នុងទម្រង់ជាសមាធិ ដែលលោកស្រី Mireille Bénisit សន្និដ្ឋានថា អាចជាព្រះឥសូរក្នុងទម្រង់ "យោគិស្វរ"។[៥] ហេតុដូច្នេះហើយ ប្រសិនបើរូបនេះពិតជា យោគិស្វរ មែន វាបានចូលទៅក្នុងផ្នែកមួយនៃការរៀបរាប់របស់លោក Rao Gopinta TA ប៉ុន្តែយ៉ាងណាយើងមិនអាចសន្និដ្ឋានឱ្យជាក់លាក់ថារូបនេះអាចចាត់ចូលក្នុងទម្រង់សិវទក្សិណាមូត្តិបានទេ ព្រោះហេតុផលសំខាន់ម្យ៉ាងទៀតនោះ គឺរូបនេះបែរព្រះភក្ត្រទៅទិសខាងកើតទេ។ រូបលេខ២ ជាចម្លាក់ព្រះឥសូរក្នុងទម្រង់ជាឥសីមានពុកមាត់វែងអង្គុយសមាធិនៅលើជើងទម្រមួយនៅគោបុរខាងលិច នៃប្រាសាទធម្មនន្ទ ដែលហ៊ុំមព័ទ្ធដោយពួកព្រាហ្មណ៍ និងទេពរង (គន្ធវ៌ ឬវិទ្យាធរ) មួយចំនួននៅពាំហែរហម។ រូបលេខ៣ ជាចម្លាក់នៅប្រាសាទអង្គរវត្តបង្ហាញអំពីព្រះឥសូរអង្គុយលើជើងទម្រក្នុងទម្រង់សុខសននៅក្រោមដើមឈើម្យ៉ាង ដោយព្រះហស្តឆ្វេងកាន់វត្ថុអ្វីម្យ៉ាង និងព្រះហស្តស្តាំកំពុងប្រទានវត្ថុអ្វីមួយទៅកាន់តួអង្គផ្សេងទៀតដែលកំពុងសំពះ និងទំនងកំពុងសណ្ដាប់នូវការបង្រៀនរបស់ទ្រង់។ រូបលេខ៤ នៅប្រាសាទបាយ័ន្ត បង្ហាញអំពីព្រះឥសូរអង្គុយនៅចំកណ្ដាលក្នុងទម្រង់ជាយោគៈ ដោយព្រះហស្តស្តាំលើកដាក់ត្រឹមដើមទ្រូវ ក្នុងកាយវិការហាក់ដូចកំពុងបង្រៀនដល់សិស្សគណដែលកំពុងនៅខាងក្រោមទ្រង់។ រូបនេះ លោក Victorio Roveda គិតថាជារូបដ៏សំខាន់ជាងគេដែលស្មើថាជា សិវទក្សិណាមូត្តិ។[៦]

ជារួមមក ទម្រង់សិវទក្សិណាមូត្តិនៅក្នុងសិល្បៈខ្មែរ អ្នកស្រាវជ្រាវហាក់ពុំទាន់អាចកំណត់ច្បាស់នៅឡើយទេ ព្រោះអ្វីដែលគួរកត់សម្គាល់នោះគឺ រូបដែលបង្ហាញខាងលើ សុទ្ធសឹងមិនដាក់បែរទៅទិសខាងត្បូង។ ប៉ុន្តែ យ៉ាងណាក៏ដោយ រូបដែលបង្ហាញទាំងអម្បាលម៉ានមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការលើកយកមកសិក្សាអំពីឥទ្ធិពលព្រហ្មញ្ញសាសនានៅសម័យបុរាណ។

## ឯកសារយោង

**Bénisti, M.** (1966). "Notes d'iconographie khmère : III. Au sujet d'un linteau de Sambor Prei Kuk", *BEFEO*, Tome 53, Paris.
**Rajarajan, R.K.K.** (2011). 'Dakṣiṇamûrti on vimānas of Viṣnu temples in far south', *South Asian Studies*, Number 27 (2): 131-144.
**Rao, G.T.A.** (1914). *Elements of Hindu Iconography,* 4 vols, Motilal Banarsidass, Delhi.
**Roveda, V.** (2005). *Image of the God.* River Book, Bangkok.

[៥] Bénisti 1966.

[៦] Roveda 2005.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ សិវទក្សិណាមូតិ៌ (?) នៅផ្ដែរទ្វារប្រាសាទសណ្ដាន់ (តំបន់ប្រាសាទសំបូរព្រៃគុក)



រូបលេខ២៖ សិវទក្សិណាមូតិ៌ (?) នៅប្រាសាទធម្មនន្ទ (រូបភាព៖ លួន ទីយា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ សិវទក្សិណាមូត៌ិ (?) នៅប្រាសាទអង្គរវត្ត (រូបភាព៖ លួន ទីយា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៤៖ សិវទក្សីណាមូត៌ិនៅប្រាសាទបាយ័ន្ត (រូបភាព៖ Roveda 2005)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី